នស/រកម/០៦០៦/០១៧

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា រក្សាឥស្សរិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិវ្រាទរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់ឃល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ឃល់ព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ឃល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់ឃល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងជែនការ

-បានទ្រង់ឃល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងជែនការ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តឃល់ព្រមលើជែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានពិនិត្យ និងផ្តល់យោបល់ឃល់ស្របលើទម្រង់ និងគតិច្បាប់ព្រមទាំងលើខ្លឹមសារនៃអត្ថបទច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

23.06.06

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើ
ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០

មាត្រា ១.-

អនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០ នេះ ។

ថ្វៃទៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ ខុម្ភៈ ឆ្នាំ ២០០៦

ភារកៈ ០៦០៦.២៨៩ ព្រះហស្តលេខា និងព្រះរាជលញ្ជីរ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

ហត្ថលេខា

អាយ ចន

លេខ: ៧៦៦៤ច.ល

ត្រឹមត្រូវចំលែក

រាជធានីភ្នំពេញ ថ្ងៃ ២៧ ខែ មិថុនា ឆ្នាំ ២០០៦

អគ្គលេខាធិការនៃអាជ្ញាធរអភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...០១...ស.រ.ប

សារាចរ
ស្តីពី
ការរៀបចំកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០)

តាំងពីបានចាប់បដិសន្ធិនាខែវិច្ឆិកា ឆ្នាំ១៩៩៣មក រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ។ ដើម្បីបានការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ប្រកបដោយចីរភាព និងមានប្រសិទ្ធភាពខ្ពស់ កន្លងមក រាជរដ្ឋាភិបាល បានរៀបចំកសាងនិងអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិសំខាន់ៗ ដែលប្រមូលផ្តុំ ទៅលើប្រជាជន និងការកាត់បន្ថយភាពក្រីក្រ ដូចជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើកទី១ (១៩៩៦-២០០០) ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើកទី២ (២០០១-២០០៥) និង យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (២០០៣-២០០៥) ។

ដើម្បីជាគុណប្រយោជន៍ដល់ការជំរុញឱ្យមានភាពលូនស៊ីសង្វាក់គ្នា រវាងបណ្តាគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលនឹងរៀបចំចងក្រងឱ្យមានឯកសារផែនការអភិវឌ្ឍន៍ជាតិតែមួយ ដោយបញ្ចូលគ្នានូវ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងដោយផ្សារភ្ជាប់នឹងគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា ។ យោងតាម **ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលដើម្បីសុខដុមនីយកម្មនិងភាពលូនស៊ីសង្វាក់គ្នា (២០០៤-២០០៨)** ដែលត្រូវបានអនុម័តនា សម័យប្រជុំគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ឯកសារផែនការថ្មីនេះ ត្រូវបានកំណត់ឈ្មោះថា : **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០)** ។

I. <u>ក្របខ័ណ្ឌទស្សនៈ</u>

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(២០០៦-២០១០) គឺជាឯកសារគោលនយោបាយជាយុទ្ធសាស្ត្រ មួយសំរាប់ការអនុវត្តន៍ចតុវិស័យនៃការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដែល :

១. ឆ្លើយតបទៅនឹងឆន្ទៈគោលនយោបាយ ដែលបានកំណត់ក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុ-កោណរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភា

២. ជាផែនការយុទ្ធសាស្ត្រមួយមានលក្ខណៈប្រកាជនិយមដែលបង្ហាញពីគោលដៅនិងកម្មវិធីទាំងឡាយ ដែលមានលក្ខណៈសមស្រប អាចអនុវត្តបាន និងអាចសំរេចបាន នៅក្នុងស្ថានភាពបច្ចុប្បន្នរបស់សង្គមជាតិ ដោយយកចិត្តទុកដាក់ដល់ចីរភាពក្នុងការគ្រប់គ្រងបរិស្ថាន សេដ្ឋកិច្ច និងសង្គមកិច្ច ។

៣. កំណត់នូវយុទ្ធសាស្ត្រមួយដែលមានលក្ខណៈរលូន ដើម្បីអនុវត្តកម្មវិធីអភិវឌ្ឍន៍ ដោយលើកឡើងពីការកំណត់អាទិភាពច្បាស់លាស់នៅក្នុងតំរូវការ គោលដៅ សកម្មភាព និងកម្មវិធីទាំងឡាយ សំដៅធានាឱ្យសំរេចបាននូវទិសដៅចម្បង។ តាមរយៈការប្រើប្រាស់ប្រកបដោយចីរភាព និង សមធម៌នូវធនធាននិងសមត្ថភាពទាំងឡាយដែលមាន និងតាមរយៈការពង្រឹងភាពជាដៃគូជាមួយ សង្គមស៊ីវិល សហគមន៍អ្នកផ្តល់ជំនួយ និងអ្នករួមចំណែកដទៃទៀត ។

៤. បង្ហាញពីក្របខ័ណ្ឌទស្សនៈ គោលនយោបាយមួយ ដែលរួមបញ្ចូលបញ្ហាប្រទាក់ក្រឡាគ្នារវាងវិស័យពាក់ព័ន្ធ ដោយធានាភាពស៊ីសង្វាក់គ្នា រវាងគោលនយោបាយ និងអន្តរាគមន៍នានា ក៏រឹតម៉ាក្រូ ក៏រឹតវិស័យ និង ក៏រឹតកម្មវិធី/គំរោង។

៥. បញ្ចូលនូវសកម្មភាពគោលនយោបាយនានា របស់ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើក ទី២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គោលនយោបាយជាតិប្រជាជន និងផែនការតាម វិស័យផ្សេងៗទៀត ដែលពុំទាន់សំរេចបាននៅក្នុងដំណាក់កាលផែនការ ហើយបន្ថែមនូវទិសដៅនិង វិធានការគោលនយោបាយអភិវឌ្ឍន៍ ដែលមានអាទិភាពខ្ពស់ សំរាប់ដំណាក់កាលប្រាំឆ្នាំខាងមុខ (២០០៦-២០១០)។

៦. ជាផែនការយុទ្ធសាស្ត្រជាតិមួយ ដែលគួបផ្សំបញ្ចូលគ្នានូវផែនការចក្ខុវិស័យ និងផែនការសកម្មភាពអាទិភាពរបស់រាជរដ្ឋាភិបាល ហើយដែលសមស្របទៅនឹងសក្តានុពលហិរញ្ញវត្ថុ និងសក្តានុពលផ្សេងៗទៀតរបស់សង្គមជាតិទាំងមូល ។

៧. ជាផែនការយុទ្ធសាស្ត្រជាតិមួយ ដែលនឹងត្រូវបានរៀបចំឡើង តាមរយៈការធ្វើឱ្យមានទំនាក់ទំនងល្អប្រសើរជាងមុននៃដំណើរការផែនការកម្ម និង ថវិកាកម្ម ។

៨. ជាឧបករណ៍មួយមានលក្ខណៈជាយុទ្ធសាស្ត្រ ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្ស កម្ពុជា ដោយបញ្ចូលគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាទៅក្នុងផែនការ និងកំណត់នូវគោលដៅ ទាំងឡាយ

ឱ្យមានភាពស៊ីសង្វាក់គ្នា ដើម្បីធ្វើឱ្យសំរេចបានការកាត់បន្ថយភាពក្រីក្រ និងទិសដៅ អភិវឌ្ឍន៍ ផ្នែក សង្គមកិច្ចផ្សេង១ទៀត សំដៅលើកកំពស់គុណភាពជីវភាពរស់នៅរបស់ប្រជាជន កម្ពុជាទាំងអស់ ។

៩. ជាឯកសារមួយ ដែលនឹងត្រូវបានរៀបចំឡើង នៅក្នុងដំណើរការមួយដែលរដ្ឋាភិបាលធ្វើអ្នកដឹកនាំ និងជាម្ចាស់ ហើយដោយមានការចូលរួមដ៏ទូលំទូលាយពីគ្រប់អ្នករួមចំណែកទាំងអស់ ។

II. <u>ក្របខ័ណ្ឌស្ថាប័នសំរាប់ដំណើរការរៀបចំផែនការ</u>

យោងតាម **ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលដើម្បីសុខដុមនីយកម្មនិងភាពរលូនស៊ីសង្វាក់គ្នា (២០០៤-២០០៨)** ដែលត្រូវបានអនុម័តនាសម័យប្រជុំគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ការរៀប ចំកសាង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០)** ត្រូវធ្វើឡើងនៅក្នុងក្របខ័ណ្ឌ ស្ថាប័ន ដូចខាង ក្រោម :

១. ក្រសួងផែនការដោយមានកិច្ចសហការជាមួយនឹងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវបង្កើតរចនាសម្ព័ន្ធ ការងារសមស្របមួយ(*ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន*) ដែលធានានូវភាពរលូននៃការ អនុវត្តន៍ ភារកិច្ចចាំបាច់សំរាប់ការរៀបចំផែនការ និងធានានូវកិច្ចសហការប្រកបដោយប្រសិទ្ធភាព ជាមួយនឹងអ្នក រួមចំណែកទាំងអស់ រួមមាន ក្រសួង-ស្ថាប័នរបស់រដ្ឋាភិបាល អង្គការអន្តរជាតិ ទីភ្នាក់របស់អង្គការ សហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ។

២. ក្រសួងផែនការត្រូវធានាការ ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នូវជំនួយបច្ចេកទេសដែលផ្តល់ ឱ្យ ដោយអង្គការអន្តរជាតិ និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិមួយចំនួន ព្រមទាំងខិតខំធ្វើ ឱ្យមានសុខដុមនីយកម្ម នៃការរួមចំណែករបស់អ្នកផ្តល់ជំនួយនៅក្នុងដំណើរការនេះ ដើម្បីទាញយក អត្ថប្រយោជន៍ឱ្យបានច្រើនបំផុត ។

៣. ក្រសួងផែនការ ត្រូវមានភារកិច្ចរៀបចំគោលការណ៍ណែនាំបច្ចេកទេស សំរាប់ក្រសួង-ស្ថាប័ន ជំនាញ ពាក់ព័ន្ធ ធ្វើការវាយតំលៃពីស្ថានភាពនៃការអនុវត្តន៍សកម្មភាពគោលនយោបាយនានា របស់ ផែនការ៥ ឆ្នាំលើកទី២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងធ្វើការរៀបចំកសាង **យុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ (២០០៦-២០១០)** នៅក្នុងវិស័យដែលខ្លួនគ្រប់គ្រង ហើយត្រូវមាន ភារកិច្ចដឹកនាំ ការផ្តល់ការណែនាំ ផ្នែកបច្ចេកទេសដល់ក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ ។

៤. តាមរយៈក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន ក្រសួងផែនការនិងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវ សហការក្នុងការងារបច្ចេកទេសជាមួយ *ក្រុមការងារចុំរះតាមវិស័យរវាងរដ្ឋាភិបាលនិងអ្នកផ្តល់* ដើម្បី ធានាឱ្យមានការចូលរួមដ៏ទូលំទូលាយមួយ និងដើម្បីពង្រឹងភាពជាដៃគូជាមួយអ្នករួមចំណែក ។

៥. ក្រសួង-ស្ថាប័នជំនាញដែលពាក់ព័ន្ធទាំងអស់ត្រូវបង្កើត*ក្រុមការងារបច្ចេកទេស*មួយ ដែលដឹកនាំ ដោយរដ្ឋលេខាធិការមួយរូប ដើម្បីដឹកនាំការរៀបចំកសាង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** នៅក្នុងវិស័យដែលខ្លួនទទួលខុសត្រូវ និងធ្វើកិច្ចសហការជាមួយនឹងក្រសួងផែនការនិងឧត្តមក្រុម ប្រឹក្សាសេដ្ឋកិច្ចជាតិ សំដៅធានានូវប្រសិទ្ធភាពនិងជោគជ័យនៅក្នុងការបំពេញភារកិច្ចរួមគ្នានេះ ។

III. <u>*កាលបរិច្ឆេទនៃការរៀបចំផែនការ*</u>

ផ្អែកតាម **ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលដើម្បីសុខដុមនីយកម្ម និងភាពល្អនស៊ីសង្វាក់គ្នា** (២០០៤-២០០៨) ការងារទាំងឡាយ ត្រូវបានគ្រោងដូចខាងក្រោម :

១. *ធ្នូ-មករា ២០០៤* ក្រសួងផែនការ ដោយមានកិច្ចសហការជាមួយនឹងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវបង្កើតជាផ្លូវការនូវយន្តការស្ថាប័នសំរាប់រៀបចំ ផែនការយុទ្ធសាស្ត្រជាតិសំរាប់អភិវឌ្ឍន៍ ដោយបង្កើត *ក្រុមការងារបច្ចេកទេសអន្តរស្ថាប័នសំរាប់ផែនការនិងការកាត់បន្ថយភាពក្រីក្រ*។

២. *មករា-ឧសភា ២០០៥* ក្រសួងផែនការ ត្រូវណែនាំឱ្យក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ រៀបចំ ផែនការយុទ្ធសាស្ត្រតាមស្ថាប័ននីមួយៗ ដោយមានការប្រជុំបច្ចេកទេស ដែលនឹងធ្វើឡើងដើម្បី ពិភាក្សាពីដំណើរការនៃការរៀបចំ ហើយត្រូវរៀបចំគោលការណ៍ណែនាំ សំរាប់ដំណើរការនៃការ រៀបចំ ។

៣. *ឧសភា-មិថុនា ២០០៥* ក្រសួង-ស្ថាប័នជំនាញ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរៀងៗខ្លួន ។

៤. *មិថុនា-សីហា ២០០៥* ក្រសួងផែនការត្រូវរៀបចំសេចក្តីព្រាងទីមួយនៃ**ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ** ដោយបញ្ចូលផែនការយុទ្ធសាស្ត្រតាមវិស័យ ដោយមានរៀបចំធ្វើសិក្ខាសាលា បច្ចេកទេស ។

៥. *សីហា-កញ្ញា ២០០៥* ក្រសួងផែនការត្រូវរៀបចំធ្វើសិក្ខាសាលាជាតិ ដើម្បីធ្វើការពិគ្រោះ យោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់ ។

៦. *កញ្ញា-តុលា ២០០៥* ក្រសួងផែនការ ត្រូវធ្វើការកែសំរួលសេចក្តីព្រាង**ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ** ដោយបញ្ចូលមតិយោបល់ ដែលបានលើកឡើងនៅក្នុងសិក្ខាសាលាជាតិ ។

៧. *វិច្ឆិកា-ធ្នូ ២០០៥* ក្រសួងផែនការធ្វើសេចក្តីព្រាងចុងក្រោយនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជូនគណៈរដ្ឋមន្ត្រីធ្វើការពិនិត្យសំរេច ហើយគណៈរដ្ឋមន្ត្រីធ្វើសេចក្តីព្រាង**ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ** ទៅសុំការអនុម័តពីរដ្ឋសភានិងព្រឹទ្ធសភា ។

រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំលើស្មារតីទទួលខុសត្រូវរបស់គ្រប់ក្រសួង-ស្ថាប័ន ក្នុងការសហការជាមួយ ក្រសួង ផែនការនិងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីធ្វើការកសាង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០)** ឱ្យទទួលបានលទ្ធផលល្អប្រសើរ សមតាមខ្លឹមសារនៃសារាចរនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមករា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ក្រៅឆ្លងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- អគ្គលេខាធិការដ្ឋានរដ្ឋសភា

-គ្រប់ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត ក្រុង

-កាលប្បវត្តិ-ឯកសារ

សម្តេច ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

សារលិខិត

ប្រជាជនកម្ពុជាបានបង្ហាញពីសមត្ថភាពតស៊ូប្តូរផ្តាច់ដ៏ធំធេងរបស់ខ្លួន និងបានធ្វើដំណើរយ៉ាងវែងឆ្ងាយ ក្នុងដំណើរការកសាងសមត្ថភាព និងស្ថាប័នឡើងវិញ បន្ទាប់ពីការរស់ភានមានជីវិតជាថ្មីនៅឆ្នាំ ១៩៧៩ ចាកផុតពីផលវិបាកនៃវិនាសកម្មស្ទើរតែទាំងស្រុង ចំពោះស្ថាប័នសង្គម និងសេដ្ឋកិច្ចជាតិ ព្រមទាំងការបំផ្លាញធនធានមនុស្សក្នុងរយៈពេលជិតបួនឆ្នាំនៃរបបប្រល័យពូជសាសន៍ប៉ុលពត ។ រដ្ឋាភិបាលកម្ពុជាទាំងអស់ដែលបានគ្រប់គ្រងប្រទេសចាប់តាំងពីឆ្នាំ ១៩៧៩ មក បានចាត់ចែងដឹកនាំដំណើរការកសាងជាតិបានយ៉ាងល្អប្រសើរ ។ ក្រោយឆ្នាំ ១៩៩៨ រាជរដ្ឋាភិបាលសម្រេច និងធានាបានន្ូវសន្តិភាពដ៏ងមាំ ដោយលុបបំបាត់បានន្ូវជម្លោះផ្ទៃក្នុងដែលធ្លាប់មានកាលពីអតីតកាល ។ ដោយប្រកាន់ខ្ជាប់គោលការណ៍ចម្បងៗនៃអភិបាលកិច្ច និងការអភិវឌ្ឍសុខមាលភាពប្រជាជន ដែលផ្តោតជាសំខាន់លើវឌ្ឍនភាព រាជរដ្ឋាភិបាលបានបានន្ូវកំណើនយ៉ាងភ្លៀវភ្លាតនៅលើគ្រប់វិស័យ ។

នៅពេលប្រទេសមួយចាប់កសាងសង្គមជាតិផ្តើមចេញពីកម្រិតក្រោមសូន្យ ដូចកម្ពុជាបានជួបប្រទះកន្លងមក ដោយត្រូវដោះស្រាយការងារអាទិភាពបន្ទាន់ចំពោះមុខជាច្រើននៅលើគ្រប់ទិដ្ឋភាពនៃសកម្មភាពសង្គមនោះ ការវិនិយោគណាមួយ ឬ ចំណាយលើអ្វីមួយ សុទ្ធតែបានរួមចំណែកដល់កំណើនសេដ្ឋកិច្ច ទោះបីក្នុងរូបភាពណាមួយក៏ដោយ ។

ដោយសម្រេចបានជោគជ័យក្នុងការជំរុញកំណើនប្រកបដោយស្ថិរភាព ក្នុងរយៈពេលជាច្រើនឆ្នាំជាប់ៗគ្នា កម្ពុជាមានការជឿជាក់លើខ្លួនឯង ហើយបានត្រៀមរៀបចំខ្លួនរួចជាស្រេចលើមាគ៌ាដ៏សំខាន់ដើម្បីធ្វើដំណើរឆ្ពោះទៅកាន់អនាគតដ៏ភ្លឺស្វាងរុងរឿង ។ ប្រជាជនកម្ពុជាបានឈានដល់ដំណាក់កាលដ៏សំខាន់មួយដើម្បីសម្លឹងមើលទៅអនាគតរបស់ខ្លួនប្រកបដោយសុទិដ្ឋិនិយម និងសេចក្តីសង្ឃឹម ។ ជម្រើសនៅចំឡាយដែលយើងបានអនុវត្ត និងជំហានទាំងឡាយ ដែលយើងបានធ្វើដំណើរមកទល់ពេលនេះ នឹងបង្ហាញឱ្យឃើញន្ូវការឆន់ឈរកន្ូវការណានុវត្តភាព និងការរួមចំណែកជារឹជ្ជមានបួយរបស់យើងទាំងអស់គ្នា សម្រាប់ការអភិវឌ្ឍនៅក្នុងទសវត្សរ៍ខាងមុខ ។ ឥឡូវនេះ គឺជាពេលវេលាមួយដែលយើងត្រូវចាប់ផ្តើមធ្វើការរុជ្រៅសបើស និងការយកជំហានដ៏ឫងទាំងឡាយ ដោយមានការផ្តោតការយកចិត្តទុកដាក់ច្បាស់លាស់ និងមានការជឿជាក់លើខ្លួនឯង ព្រមទាំងមានឆន្ទៈយ៉ាងមោះមុត ។

កម្រិតនៃភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ ១៩៩៣ [illegible] អង្កេតជាហូរហែកន្លងមក ។ ការធ្លាក់ចុះនៃអត្រាភាពក្រីក្របានកើតឡើង ជាពិសេស[illegible]

គឺជាពេលវេលាមួយដ៏សមស្រប ដែលធនធានទាំងឡាយនឹងត្រូវបានយកមកប្រើប្រាស់ចំទិសដៅ និង ប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ប្រយោជន៍ជាអតិបរមាចំពោះប្រជាជនទន់ខ្សោយ និង ងាយរងគ្រោះ ដើម្បីជួយលើកស្ទួយពួកគេ ឱ្យបានចូលរួមក្នុងចរន្តគោលនៃការអភិវឌ្ឍ ។

ដោយពង្រឹង និង ស្ថាបនា លើមូលដ្ឋាននៃសមិទ្ធផលទាំងឡាយ ដែលសម្រេចបានពីពេលមុនៗ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ ២០១៥ ដែលផ្តោតលើការអភិវឌ្ឍមនុស្សជាតិ តាមរយៈ *«យុទ្ធសាស្ត្រចតុកោណ»* បន្តពី *«យុទ្ធសាស្ត្រត្រីកោណ»* របស់រាជរដ្ឋាភិបាល សម្រាប់គោលដៅរួម ដែលមានការរៀបចំគិតគូរច្បាស់លាស់ ក៏ដូចជាសម្រាប់ការវិនិយោគ និង កំណើនចំពោះបណ្តាវិស័យអាទិភាព ។ កំណើនសេដ្ឋកិច្ច និង សង្គម ត្រូវមានលក្ខណៈសមធម៌ និង ជាកាលានុវត្តភាព និងជាផ្លែផ្កា ដែលទាំងអស់គ្នាអាចប្រើប្រាស់ និងទទួលបានទាំងតាមភូមិសាស្ត្រនីមួយៗ ទាំងសម្រាប់អ្នកមាន និង អ្នកក្រ ។ យើងត្រូវប្រើប្រាស់ធនធានដ៏តិចតួចស្ដួចស្ដើង ដើម្បីផលប្រយោជន៍ជាអតិបរមារបស់ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសសម្រាប់អ្នកក្រីក្រ ហើយមិនត្រូវទុកឱ្យការវិនិយោគក្នុងវិស័យសាធារណៈជាជម្រើស ឬ ការសម្រេចចិត្តរបស់អ្នកក្រៅផ្សេងឡើយ ។

រាជរដ្ឋាភិបាលទទួលស្គាល់ថា វឌ្ឍនភាពដែលយើងសម្រេចបានយ៉ាងធំធេងចាប់តាំងពីឆ្នាំ ១៩៩៣ មក គឺដោយសារមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេសដ៏ច្រើនសន្ធឹកពីសំណាក់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសរបស់យើង ។ យើងសូមសម្តែងនូវការដឹងគុណចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់នោះ ។ ទោះជាយ៉ាងនេះក្តី ច្បាស់ណាស់ថា ធនធានក្រៅប្រទេសយ៉ាងច្រើនកាលពីអតីតកាល ត្រូវបានប្រើប្រាស់ផ្តាល់ដោយអ្នកផ្តល់ជំនួយទាំងនោះ ក្នុងកម្មវិធី និង សកម្មភាពទាំងឡាយ ដែលជាជម្រើសរបស់ពួកគេ ក្រៅពីក្របខ័ណ្ឌនៃការទទួលខុសត្រូវ ឬ ការពិនិត្យពិច័យរបស់រាជរដ្ឋាភិបាល ។ ជំនួយមួយចំណែកធំត្រូវបានចាយលើផ្នែកអរូបិយនៃការអភិវឌ្ឍ ដូចជាជំនួយបច្ចេកទេសជាដើម ។ ទោះជាដូច្នេះក្តី នៅពេលអនាគត រាជរដ្ឋាភិបាលនឹងទទួលបន្ទុកពេញលេញនៅក្នុងដំណើរការទាំងមូល ហើយធានាថាធនធានទាំងអស់របស់រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស នឹងត្រូវតម្រង់ទិសច្បាស់លាស់ចំពោះអាទិភាព និង វិស័យទាំងឡាយដែលជ្រើសរើសដោយរាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តបន្ថែមទៀត ដើម្បីធានាថា សមាមាត្រដ៏ខ្ពស់បំផុតនៃមូលនិធិពីក្រៅប្រទេស នឹងត្រូវបានប្រើប្រាស់ជា *«ហិរញ្ញប្បទាន»* សម្រាប់ការអភិវឌ្ឍ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ (ផយអជ) ដែលត្រូវបានរៀបចំឡើងដោយឈរលើ *យុទ្ធសាស្ត្រចតុកោណ* របស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយការគិតគូរគ្រប់ជ្រុងជ្រោយលើគ្រប់វិស័យ តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយគ្រប់ដៃគូទាំងអស់ និងជាលទ្ធផលនៃការច្រចាច់បញ្ចូលគ្នានូវឯកសារនានា មានជាអាទិ៍ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គោលនយោបាយជាតិស្រាវជ្រាវ* ។ល។ គឺជាក្របខ័ណ្ឌ និងជាគ្រឹះវិស័យតែមួយគត់សម្រាប់ការជម្រុញ *ឥរិយាបថ* ការបង្កើត *ការងារ* ការធានា

ប្រសិទ្ធភាព ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងការអភិវឌ្ឍប្រកបដោយសមធម៌ ដោយមានការតម្រង់ទិសច្បាស់លាស់សម្រាប់ពេលអនាគត និងមានចរិតគាំទ្រប្រជាជនក្រីក្រ និងការ-អភិវឌ្ឍជនបទ ។ *ដំណាក់* នេះ នឹងនាំប្រទេសជាតិឆ្ពោះទៅកាន់មាគ៌ាមួយរីកចម្រើនពិតប្រាកដ និងប្រកបដោយចីរភាព តាមរយៈការកំណត់ទស្សនៈវិស័យ គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាព សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ ។ *ដំណាក់* ធ្វើការវិភាជន៍ធនធានប្រកបដោយតុល្យភាពប្រកបដោយនិរន្តរភាព និងអាចអនុវត្តបានសម្រាប់គ្របវិស័យឈរលើមូលដ្ឋានអាទិភាពកម្ម ។ ដូច្នេះការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០* នឹងទទួលបាននូវការតាមដានត្រួតពិនិត្យ ដោយយកចិត្តទុកដាក់ និងជាប្រចាំ ដើម្បីធ្វើការកែតម្រូវប្រចាំឆ្នាំ ។

រាជរដ្ឋាភិបាលទទួលស្គាល់ពីភាពចាំបាច់ចម្បងៗ ក្នុងការបង្កើត និងពង្រឹងស្ថាប័នអភិបាលកិច្ចដំណើរការ និងនីតិវិធីឱ្យបានប្រសើរជាងមុន តាមរយៈកំណែទម្រង់ដែលមានផែនការច្បាស់លាស់ សំដៅធានាបានការអភិវឌ្ឍប្រកបដោយចីរភាព ។ យ៉ាងណាមិញ *«សង្គ្រាមត្រូវ»* មិនមែនកសាងតែក្នុងរយៈពេលមួយថ្ងៃហើយនោះទេ ចំណែកឯស្ថាប័នរបស់ប្រទេសកម្ពុជាទាំងមូល ដែលត្រូវបានបំផ្លិចបំផ្លាញដល់ឫសគល់ក៏មិនអាចកសាងឡើងវិញ តែក្នុងរយៈពេលមួយយប់នោះបានដែរ ក្នុងនោះរួមមាន ការកសាងស្ថាប័នសេដ្ឋកិច្ច សង្គមកិច្ច រដ្ឋាភិបាល ហិរញ្ញវត្ថុ និងស្ថាប័នផ្សេងៗទៀត ។ ប៉ុន្តែជាជំហានៗ វឌ្ឍនភាពបានកើតមានជាបន្តបន្ទាប់ ហើយបានចាប់ផ្តើមក្នុងជំហានដ៏ធំរហ័ស ដែលមិនធ្លាប់បាននៅតែន្លែងផ្សេងទៀតនៃពិភពលោក ។ ការអនុវត្តជាក់ស្តែងនូវកំណែទម្រង់នានា និងការអនុវត្តន៍ច្បាប់ និងនីតិវិធីទាំងឡាយនឹងអាចបំពេញប្រព័ន្ធទាំងមូលក្នុងរយៈពេលមួយជាក់លាក់ ដោយរបៀបរបបការងារល្អប្រសើរ ហើយអាចផ្សារភ្ជាប់ និងពង្រឹងស្ថាប័ននានា ដែលមានសារសំខាន់សម្រាប់លទ្ធិប្រជាធិបតេយ្យ ដូចដែលមាននៅទី-កន្លែងផ្សេងទៀតក្នុងពិភពលោក បើទោះបីជាត្រូវការប្រើពេលវេលាយូរក៏ដោយ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ គឺជាផែនការបួយសម្រាប់វឌ្ឍនភាពបន្តទៀត លើការកសាងកម្ពុជាថ្មីមួយ ហើយជាឯកសារគ្រប់ជ្រុងជ្រោយតែមួយគត់របស់រាជរដ្ឋាភិបាលសម្រាប់ការអនុវត្តរយៈពេល ៥ ឆ្នាំខាងមុខ ។

ខ្ញុំសូមអំពាវនាវដល់ក្រសួង-ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់ សូមប្រកាន់ខ្ជាប់យ៉ាងហ្មត់ចត់ចំពោះអាទិភាពទាំងឡាយ ដែលបានលើកឡើងនៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០* នេះ ។

ភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៦

ហ៊ុន សែន